ឌ

ឌ ព្យញ្ជនៈទី ១៣ ក្នុងវគ្គទី ៣ ជាឃោសៈ មានសំឡេងកើតក្នុងត្បូង ឡើងក្នុងពួកសំឡេង ៥ មុទ្ធជៈ, ជាសិថិលឃោសៈ (ភាង សំ. បា. អ. ថ. ឌ: (ឌ: ឌ្ហ:), បើកមាត់រលាស់ចុងអណ្ដាតទៅខាងលើ, កុំឲ្យដូច ឌ: ឌ្ហ: ដែលរលាស់ចុងអណ្ដាតឲ្យប៉ះត្រង់ប្រទល់ធ្មេញ) ។ ព្យញ្ជនៈ ឌ នេះ, សម្រាប់ភាសា សំ. និង បា. ឃើញមានប្រើជា *ដើមពាក្យ* ឬជា *មេពាក្យ* ខ្លះបន្តិចបន្តួច ដូចជា *ឌំស* "រោម"; *ឌាក* "ប្រើក, វឹកជ្រក់"; *ឌាហ* "សេចក្ដីក្ដៅក្រហាយ, សេចក្ដីអន្ទះអន្ទែងភ្លើង" ជាដើម; បើជាក់រៀងត្រង់កណ្ដាលឬត្រង់ខាងចុងនៃពាក្យផងទៀតនោះឃើញមានប្រើក្រៃលែង ដូចជា *ចណ្ឌ, ចណ្ឌាល, ប្រចណ្ឌ, បណ្ឌិត, កណ្ឌ:, មណ្ឌប, មណ្ឌល, សណ្ឌាស* ជាដើម (ម. ព. តំរួតនោះ)ៈ ឯភាសាខ្មែរយើងមិនហៃប្រើសោះឡើយ, ដែលមានខ្លះនោះក៏សុទ្ធតែយកភាសាដទៃមកប្រើ ដូចពាក្យដែលមានតទៅនេះ ។

ឌមជន (ឌៈ មៈ ជន់) *ន.* (សំ. ឌម + ជន) អ្នកធ្វើការល្បួលយ៉ាងចោរ មានចោរកំសំកេម, និងទឹកសន្ទុះចោល ជាដើម : *ពួកឌមជន* ។

ឌាកិនី *ន.* (សំ.) បិសាចស្រី ឬស្រីបិសាច ។

ឌាឌិម ឬ **ឌាលិម** *ន.* (សំ.) ទទឹម, ផ្លែទទឹម ។

ឌាហរោគ (ដាហៈ—) រោគក្ដៅក្រហាយ, ជំងឺក្ដៅអន្ទះអន្ទែងក្នុងកាយ, ជំងឺគ្រុនក្ដៅ ។

ឌិកតេ *ន.* (បា. Dictée) ការសរសេរតាមពាក្យដែលគេសូត្រ, គេអាន គឺមានអ្នកអានសេចក្ដីអ្វីមួយជាបន្តរ៉ាៗ តាមល្បឿន តាមសង្កាត់ឲ្យអ្នកស្ដាប់សរសេរតាម : *ធ្វើឌិកតេ, រៀនឌិកតេ, សូត្រឌិកតេ* ។ ខ្មែរយើងប្រើពាក្យនេះជា *កិ.* ក៏មាន : *កំពុងឌិកតេ* ។ ពាក្យនេះហៅជាខ្មែរថា *សរសេរតាមសូត្រ* ឬ *សរសេរតាមអាន* ។

ឌិន *ន.* (ស. ដ៉ែន អ.ថ. ឌិន) គ្រឿងពិច្របធ្វើដោយប្រាក់, មាស, ស្ពាន់ ឬលាយមាស (ធ្វើមកពីប្រទេសសៀម) សម្រាប់ដាក់គ្រឿងប្រដាប់ប្រើជាសំអាងស្លៀង : *ឌិនប្រាក់, ឌិនមាស, ឌិនស្ពាន់* ។

ឌី *កិ.* (ស. ឌ៉ី អ.ថ. ឌី ឬ ឌ៉ីឌ៉ី អ.ថ. ឌីឌី *គុ.* "ដែលមិនជឿស្ដាប់, តំណាកស្អីថា, ប្រឆាំង") រឹងទទឹង, និយាយរឹង : *ស្អីប្រាប់ទៅ កាន់ឌីមកវិញ; ខឹងឌីចិត្ត* ។ *កិ. វិ. និយាយឌី, ដេរឌី* ។

ឌីជង *កិ.* (ស. ឌ៉ីជ៉ាន អ.ថ. ឌីជាន *គុ.* ដែលប្រឆាំង, ដែលចចេស តំណាកស្អីថា; ដែលរឹង, មិនចុះ "ក៏បិត",...) និយាយជំទាស់, និយាយបញ្ចៀសកសាងឡើងខ្លួន, ឡើងក, ឡើងចិត្ត : *កាលណាគេឌីជងឲ្យទំ, ស្មើតែមិនចប់មិនឈ្នះ, ព្រឹកឌីជងល្ងាចឌីជង, ប្រហែលជាមិនចប់ពុំបាននេះជើង ?*

ឌុជាន់ *កិ.* (ស. *ឌុជ៉ាន* អ.ថ. *ឌុជាន់* *គុ.* "ដែលរឹងរូស ស្អីថា, លោកព្រាមមិនស្ដាប់; ការ") រឹងក, និយាយកកែកករ ។ តករៀងរកហេតុ, និយាយត្រកួន, និយាយពាក់ព័ន, ញុះញង់ ។ គ្រើនប្រើក្លាយមកជា *ឌុកជាន់* ។

ឌុកជាន់ (ម. ព. *ឌុជាន់*) ។

ឌុន *គុ.* ឬ *ន.* (ស. *ឌុល្យ* អ.ថ. *ឌុន;* ក្លាយមកពី សំ. បា. *តុល្យ*) ដែលស្មើគ្នា, ដែលស្របគ្នា, ដូចគ្នា : *ពាក្យឌុនគ្នា, សេចក្ដីឌុនគ្នា* (មិនសូវប្រើ) ។ ម. ព. *តុល្យ* និង *តុល្យាធិករណ:* ផង ។

ឌេបនកម្ម (ឌេប៉ៈ នៈ កំ) *ន.* (បា.) ការប្រហារ, ការតិបាត ឬ វិឃាតកម្ម ។

ឌេបនាការ (ឌេប៉ៈណាក) *ន.* (បា.) អាការបោះពោល : *ធ្វើឌេបនាការ* ។